ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 03-Nov-2011, 15:58
CMS/CFO: Uch Arun

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

**សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យបង្កើតប្រព័ន្ធមានប្រសិទ្ធិភាពមួយ**
**សម្រាប់ការទទួលយកភស្តុតាងជាឯកសារនៅពេលសវនាការ**

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូន: |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | អៀង ធីរិទ្ធ |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម យូ ឧត្តរា | |
| | | មេធាវីការពារក្ដីជនជាប់ចោទ: |
| | សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី: | លោក សុន អរុណ |
| | | លោក Michiel PESTMAN |
| | ពេជ អង្គ | លោក Victor Koppe |
| | Elisabeth SIMONNEAU FORT | លោក អាង ឧត្តម |

លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក សរ សូវាន
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូង ថ្មីៗនេះបានចេញសេចក្តីណែនាំដល់គូភាគីនានាទាក់ទងនឹងឯកសារដែលត្រូវទទួលយកពាក់ព័ន្ធនឹងសាក្សី និងភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលអាចនឹងត្រូវបានកោះហៅមកបំភ្លឺក្នុងអម្លុងពេលបីសប្តាហ៍ដំបូងនៃសវនាការ ។ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងផ្តល់ការណែនាំបន្ថែមដល់គូភាគី ទាក់ទងនឹងការទទួលយកភស្តុតាងជាឯកសារ។

២. ដើម្បីឱ្យកាន់តែជាក់លាក់ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង (១) បញ្ជាក់អះអាងថា គូភាគីនឹងត្រូវបានអនុញ្ញាតឱ្យដាក់ឯកសារដោយផ្ទាល់ជូន អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការផ្តល់ជូនឯកសារតាមរយៈសាក្សីនានា; (២) បង្គាប់ថា ឯកសារទាំងឡាយដែលបានបញ្ចូលក្នុងបញ្ជីឯកសាររបស់គូភាគី និងដែលមិនមានការជំទាស់ដោយភាគីប្រឆាំង ត្រូវបានទទួលយកជាភស្តុតាង ដោយពុំចាំបាច់មានការសួរនាំបន្ថែម; (៣) លៃលកបែងចែកឱ្យមានការប្រជុំក្នុងពេល សវនាការសម្រាប់ការទាញហេតុផលផ្ទាល់មាត់ ដែលនឹងត្រូវកើតមានឡើងនៅពេលមានការជំទាស់ណាមួយដោយគូភាគី ឬមានកង្វល់ណាមួយដែលបានលើកឡើងដោយអង្គជំនុំជម្រះខ្លួនឯងផ្ទាល់ចំពោះឯកសារជាក់លាក់ណាមួយ និង (៤) ផ្តល់លេខ E3 ជាបន្ទាន់ចំពោះឯកសារដែលបានទទួលយករួចហើយ ។

## II. ប្រវត្តិនីតិវិធី

៣. នៅក្នុងសម័យប្រជុំស្តីពីការគ្រប់គ្រងសវនាការ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានកំណត់អត្តសញ្ញាណប្រធានបទចំនួនបួន ដែលត្រូវគ្របដណ្តប់ក្នុងដំណាក់កាលដំបូងនៃសវនាការសំណុំរឿង ០០២[1]។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ ក្នុងអម្លុងពេលសវនាការបឋម អង្គជំនុំជម្រះសាលាដំបូង បានស្នើឱ្យគូភាគីដាក់បញ្ជីឯកសារដែលនឹងត្រូវទទួលយកនៅក្នុងអម្លុងពេលដំណាក់កាលដំបូងនេះ (បញ្ជីឯកសារដំណាក់កាលដំបូង)[2]។ សហព្រះរាជអាជ្ញា បានដាក់បញ្ជីឯកសារដំណាក់កាលដំបូងរបស់ខ្លួន ក្នុងចម្លើយតបទៅនឹងដីកាសម្រេចនេះ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១[3] ។

៤. នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញអនុស្សរណៈមួយ ដោយបានកំណត់អត្តសញ្ញាណសាក្សី ៥រូប និងដើមបណ្តឹងរដ្ឋប្បវេណី ៣រូប ដែលអាចនឹងត្រូវបានកោះហៅ

---

[1] E1/2.1 ប្រតិចារិក, កិច្ចប្រជុំរៀបចំសវនាការ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១, ទំព័រទី៥២ ។

[2] E1/4.1 ប្រតិចារិកនៃសវនាការបឋម, ២៧ មិថុនា ២០១១, ទំព័រទី២៥ ។

[3] E109/4 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំឯកសារដែលទាក់ទងនឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី, ២២ កក្កដា ឆ្នាំ២០១១ ។

ក្នុងរយៈពេលបីសប្តាហ៍ដំបូងនៃសវនាការដំបូងនេះ (“អនុស្សរណៈ”)[4]។ អនុស្សរណៈនេះ បានបង្គាប់ឱ្យគូភាគីនានាបង្ហាញអំពីឯកសារនិងវត្ថុតាងណាខ្លះ ពីបញ្ជីឯកសារដំណាក់កាលដំបូងរបស់ខ្លួន ដែលចង់ឱ្យទទួលយក ពាក់ព័ន្ធនឹងសាក្សី និងជំនាញទាំងនោះ មិនឱ្យហួសពីថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១១។ អនុស្សរណៈបានបង្គាប់ឱ្យភាគីដាក់ការជំទាស់ណាមួយទៅនឹងបញ្ជីឯកសារ និងវត្ថុតាងដែលបានស្នើឡើងដោយភាគីប្រឆាំង ក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីការជូនដំណឹងរបស់ពួកគាត់។ អនុស្សរណៈនេះ ក៏បង្គាប់បន្ថែមឱ្យគូភាគីបង្ហាញ មិនឱ្យហួសពីថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ អំពីឯកសារណាមួយ ប្រសិនបើមាន ដែលបានដាក់បញ្ចូលក្នុងបញ្ជីឯកសារដំណាក់កាលដំបូងរបស់ភាគីប្រឆាំងដែលខ្លួនបានជំទាស់ និងអំពីមូលដ្ឋានសម្រាប់ការតវ៉ាទាំងនេះ។

៥. នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១១ សហព្រះរាជអាជ្ញា បានដាក់សេចក្តីជូនដំណឹងមួយ និងបញ្ជីឯកសារអម ដោយកំណត់អត្តសញ្ញាណឯកសារចំនួន៩៧៨ច្បាប់ ដែលសហព្រះរាជអាជ្ញានឹងស្វែងរកឱ្យទទួលយកពាក់ព័ន្ធនឹងសាក្សី ៥រូប និងដើមបណ្តឹងរដ្ឋប្បវេណី ៣រូប ដែលអាចនឹងត្រូវបានកោះហៅក្នុងរយៈពេលបីសប្តាហ៍ដំបូងនៃសវនាការដំបូង[5]។ សហព្រះរាជអាជ្ញា បានជូនដំណឹងបន្ថែមដល់អង្គជំនុំជម្រះសាលាដំបូង និងគូភាគីដទៃទៀតថា សហព្រះរាជអាជ្ញាអាចស្វែងរកឱ្យមានការទទួលយកឯកសារដទៃទៀត ពីក្នុងបញ្ជីឯកសារដំណាក់កាលដំបូងរបស់ខ្លួន ដែលពាក់ព័ន្ធនឹងសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះ ប្រសិនបើមានតម្រូវការ[6]។

## III. សំណើ

## ក. ការបង្ហាញជូនឯកសារដោយផ្ទាល់ដល់អង្គជំនុំជម្រះសាលាដំបូង

៦. សហព្រះរាជអាជ្ញាសង្កេតឃើញថា ក្រៅអំពីការបង្គាប់ឱ្យគូភាគីនានាកំណត់អត្តសញ្ញាណឯកសារដែលត្រូវបង្ហាញពាក់ព័ន្ធនឹងសាក្សី និងភាគីដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានចេញនូវសេចក្តីណែនាំណាមួយនៅឡើយ អំពីទម្រង់ផ្សេងៗដទៃទៀតសម្រាប់ការបង្ហាញភស្តុតាង។ អាស្រ័យហេតុនេះ មានការស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ចេញសេចក្តីណែនាំដូច្នេះ និងដើម្បីឱ្យជាក់លាក់ សូមបញ្ជាក់អះអាងថា បន្ថែមលើឯកសារដែលអាចនឹងត្រូវបានផ្តល់

[4] E131/1 អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង ពេលវេលាកំណត់សម្រាប់ការដាក់ឯកសារតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5, ២៥ តុលា ២០១១ (សំណៅនៃអនុស្សរណៈដែលផ្តល់ជូនជាមុនទុកជាការគួរសម ត្រូវបានបញ្ជូនមកភាគីនានាតាមរយៈអ៊ីម៉ែលនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១) ។

[5] E131/1/4 សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញា អំពីឯកសារដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញទាំងឡាយដែលត្រូវកោះហៅក្នុងអំឡុងពេលបីសប្តាហ៍ដំបូងនៃសវនាការ ជាមួយនឹង ឧបសម្ព័ន្ធ ក សម្ងាត់, ១ វិច្ឆិកា ២០១១ ។

[6] *ក្នុងឯកសារដដែលដូចខាងលើ*, ត្រង់កថាខ័ណ្ឌទី៣ ។

ជូនដោយសាក្សី ភាគីដើមបណ្តឹងរដ្ឋប្បវេណី អ្នកជំនាញ និងជនជាប់ចោទ (បើពួកគេជ្រើសយកការចូលបំភ្លឺ) គូភាគីនានានឹងត្រូវបានអនុញ្ញាតឱ្យដាក់ឯកសារដោយផ្ទាល់ជូន អង្គជំនុំជម្រះសាលាដំបូង សម្រាប់ការបង្ហាញភស្តុតាងនៅទូទាំងសវនាការទាំងមូល។

៧. ដើម្បីជាការគាំទ្រចំពោះសំណើនេះ សហព្រះរាជអាជ្ញា កត់សម្គាល់ថា មិនមានគោលការណ៍ស្តីពីភស្តុតាងនោះទេនៅ អវតក ឬនៅក្នុងនីតិវិធីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលតម្រូវឱ្យឯកសារទាំងឡាយ ដែលត្រូវស្នើសុំផ្តល់ជូនជាផ្លូវការ ដើម្បីធ្វើជាភស្តុតាងតាមរយៈសាក្សី។ វិធាន៨៧.២ នៃវិធានផ្ទៃក្នុងចែងថា គឺមានតែភស្តុតាងដែល "ត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងដែលត្រូវបានឆ្លងកាត់ការដេញដោលតែប៉ុណ្ណោះ" ដែលអាចឱ្យអង្គជំនុំជម្រះពឹងផ្អែកលើបាននៅក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន។ វិធាន៨៧.៣នៃវិធានផ្ទៃក្នុងបំភ្លឺថា ភស្តុតាងណាមួយត្រូវបានចាត់ទុកជាត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬភាគី បើសិនជាខ្លឹមសាររបស់វាត្រូវ"បានសង្ខេប" ឬត្រូវបានអានឬត្រូវបានកំណត់អត្តសញ្ញាណសមស្របនៅក្នុងតុលាការ"។ គ្មានលក្ខខណ្ឌតម្រូវនៅក្នុងវិធានផ្ទៃក្នុងថាភស្តុតាងត្រូវតែបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួមគ្នាជាមួយនឹងចម្លើយសាក្សីនោះឡើយ។

៨. នៅក្នុងការបកស្រាយលើវិធាន៨៧នៃវិធានផ្ទៃក្នុងកាលពីមុន អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ឯកសារដែលនៅក្នុងសំណុំរឿង "ត្រូវតែបង្ហាញជូន"នៅក្នុងសវនាការនៅមុនពេលតុលាការធ្វើការពិនិត្យពិចារណាលើភស្តុតាង ប៉ុន្តែតុលាការមិនបានកំរិតថាឱ្យការបង្ហាញជូននេះត្រូវតែធ្វើរួមគ្នាជាមួយនឹងសក្ខីកម្មរបស់សាក្សីនោះទេ[7]។ នៅក្នុងលក្ខណ្ឌដែលតម្រូវឱ្យភស្តុតាងត្រូវតែ "ឆ្លងកាត់ការសួរដេញដោល" នោះ អង្គជំនុំជម្រះបានសម្រេចថា លក្ខខណ្ឌនេះអាចបំពេញបានសំរេចក្នុងករណីបើសិនជា "ឱកាសត្រូវបានបើកឱ្យសម្រាប់ធ្វើការលើកទឡ្ហីករណ៍តទល់គ្នាadversarial argument ទោះបីជាភាគីនានាមិនបានប្រើប្រាស់នូវឱកាសនេះក៏ដោយ"[8]។ ជាថ្មីម្តងទៀត អង្គជំនុំជម្រះសាលាដំបូង មិនបានកម្រិតឱ្យចំពោះការដេញដោលនេះ តែនៅក្នុងបរិបទនៃសក្ខីកម្មរបស់សាក្សីនោះទេ។ ស្របតាមការបកស្រាយនេះ នៅក្នុងសំណុំរឿងលេខ០០១ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់ដល់ភាគីនានា នៅពេលចុងបញ្ចប់ នៃរាល់ការផ្តល់សក្ខីកម្មរបស់សាក្សីទាំងអស់នូវ

[7] សូមអានឯកសារលេខ E43/4 , សេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាននៃឯកសារនៅក្នុងសំណុំរឿងដែលជាភស្តុតាង សំណុំរឿងលេខ០០១, ចុះថ្ងៃទី២៦ ឧសភា ២០០៩, ត្រង់កថាខណ្ឌទី៥-៦។ E176 សេចក្តីសម្រេចលើសំណើរបស់ភាគីក្នុងការដាក់សម្ភារៈភស្តុតាងមួយចំនួននៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន៨៧(២) នៃវិធានផ្ទៃក្នុងសំណុំរឿងលេខ០០១ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៩ (សេចក្តីសម្រេចដាក់សម្ភារៈភស្តុតាង)ត្រង់កថាខ័ណ្ឌទី២

[8] ឯកសារលេខ E176, សេចក្តីសំរេចលើឯកសារ, *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី២។

ឱកាសដើម្បីដាក់ឯកសារបន្ថែមនៅចំពោះមុខខ្លួន ហើយបន្ទាប់មកទៀតអង្គជំនុំជម្រះបានទទួលយកនូវឯកសារមួយចំនួនក្នុងចំណោមឯកសារទាំងនោះបញ្ចូលជាភស្តុតាង[9]។

៩. បន្ទាប់ពីសំណុំរឿង ០០១ មក វិធាន៨០(៤) ថ្មី ត្រូវបានអនុម័តដើម្បីផ្តល់ឱ្យបានជាក់លាក់ដល់គូភាគីដើម្បីដាក់ការជំទាស់ជាលាយល័ក្ខអក្សរ *នៅមុនពេលសវនាការ*ចំពោះឯកសារណាដែលភាគីប្រឆាំង បាន និងកំពុងតែស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង នៅពេលសវនាការ[10] ។ គោលបំណងនៅពីក្រោយវិសោធនកម្មវិធាននេះ ច្បាស់ណាស់គឺដើម្បីជួយសម្រួលដល់ការត្រៀមរៀបចំ និងការគ្រប់គ្រងសវនាការ តាមរយៈការអនុញ្ញាតឱ្យមានដំណោះស្រាយចំពោះបញ្ហាទាក់ទងនឹងភាពអាចទទួលយកបាននៃភស្តុតាងជាឯកសារ នៅមុន និងដាច់ពីសក្ខីកម្មសាក្សីនៅពេលសវនាការ ។

១០. នៅកម្រិតអន្តរជាតិ នេះគឺជាការអនុវត្តជារួមទូទៅនៃការស្នើផ្តល់ជាផ្លូវការនូវភស្តុតាងជាឯកសារដោយមិនបាច់ឱ្យសាក្សីជាអ្នកដាក់បញ្ចូល។ នៅក្នុងករណីរឿងក្តីរបស់ *Katanga* តុលាការព្រហ្មទណ្ឌអន្តរជាតិបានបង្កើតឡើងនូវវិធានទូទៅមួយដែលនៅក្នុងករណីនោះ ដែលគាំទ្រដល់ការដាក់បញ្ចូលនូវភស្តុតាងជា ឯកសារ(ក្រៅពីកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃភស្តុតាងជាសក្ខីកម្មរបស់សាក្សីដោយឡែកណាម្នាក់) ដោយឯករាជ្យដាច់ចេញដោយឡែកពីសាក្សី[11]។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានសង្កេតឃើញថា វិធីសាស្ត្រនេះមានការចាំបាច់ "ដើម្បីជៀសវាងនូវសេចក្តីត្រូវការក្នុងការកោះ ហៅសាក្សីមួយចំនួនធំ ដើម្បីឱ្យគ្រាន់តែឱ្យមកដាក់បញ្ចូលឯកសារតែប៉ុណ្ណោះ"[12]។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងនៅតុលាការICTY[13] នឹង ICTR[14] ជា

[9] ឯកសារលេខ E176, សេចក្តីសំរេចលើឯកសារ, *ដូចគ្នានឹងខាងលើ*។

[10] វិធាន៨០(៣) និង (៤) ដែលបានដាក់បញ្ចូលនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១១ ។

[11] ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង *Germain Katanga and Mathieu Ngudjolo Chui*, សុំណុំរឿងលេខ ICC-01/04-01/07, សេចក្តីណែនាំសំរាប់ការដឹកនាំដំណើរការនីតិវិធី និងការផ្តល់សក្ខីកម្មរបស់សាក្សី (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICC), ចុះថ្ងៃទី២០ វិច្ឆិកា ២០០៩ ។

[12] *ដូចគ្នានឹងខាងលើ* ត្រង់កថាខណ្ឌទី៩៨។

[13] *សូមអាន ឧទាហរណ៍ដូចជា* ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង *Momčilo Perišić*, សំណុំរឿងលេខ IT-04-81-T, ដីកាសំរាប់ជាសេចក្តីណែនាំស្តីពីការទទួលយក និងការបង្ហាញភស្តុតាង (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី២៩ តុលា ២០០៨ ត្រង់កថាខណ្ឌទី២២ ។ ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង *Milan Martić,* សំណុំរឿងងលេខ IT-95-11-T, សេចក្តីសំរេចអនុម័តលើសេចក្តីណែនាំស្តីពីបទដ្ឋានសំរាប់គ្រប់គ្រងការបង្ហាញភស្តុតាង (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី១៩ ឧសភា ២០០៦ ត្រង់កថាខណ្ឌទី១៥។ ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង *Sefer Halilović*, សំណុំរឿងលេខ IT-01-48-AR73.2, សេចក្តីសំរេចលើបណ្តឹងឧទ្ធរណ៍ស្តីពីបញ្ហាបន្ទាន់បន្ទំ ទាក់ទងនឹងការទទួលយកនូវកំណត់ហេតុស្តីពីការសួរចម្លើយជនជាប់ចោទពីតុនៃអង្គចៅក្រម ( from the Bar Table), ចុះថ្ងៃទី១៩ សីហា ២០០៥ ត្រង់កថាខណ្ឌទី១៤។

ទម្លាប់អនុវត្តន៍ធម្មតា បានអនុញ្ញាតឱ្យដាក់បញ្ចូលនូវភស្តុតាងជាឯកសារដោយផ្ទាល់ពីអង្គចៅក្រម (directly from the bar table)។

១១. ការអនុញ្ញាតឱ្យដាក់បញ្ចូលភស្តុតាងជូនទៅអង្គជំនុំជម្រះដោយផ្ទាល់ នឹងជួយលើកស្ទួយឱ្យការជំនុំជម្រះក្តីបានប្រកបដោយភាពត្រឹមត្រូវ ឆាប់រហ័ស និងមានប្រសិទ្ធិភាពដោយសារការណ៍នេះនឹងជួយឱ្យអង្គជំនុំជម្រះសាលាដំបូង អាចមានលទ្ធភាពធ្វើការពិនិត្យពិចារណាបានដោយត្រឹមត្រូវទៅលើភស្តុតាងពាក់ព័ន្ធ និងដែលមានភវនីយភាពក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ ដែលមានស្រាប់ដែលបានស្នើឡើងដោយភាគីនានា ដើម្បីធានាឱ្យប្រាកដថាពេលវេលាក្នុងការផ្តល់សក្ខីកម្មរបស់សាក្សីមិនត្រូវបានចំណាយខ្ជះខ្ជាយ ដោយមិនត្រឹមត្រូវទៅលើការទាញអំណះអំណាងផ្លូវច្បាប់ ទាក់ទងទៅនឹងភាពអាចទទួលយកបាននៃឯកសារនិងកាត់បន្ថយចំនួនសាក្សីដែលចាំបាច់ត្រូវកោះហៅ។

## ខ. ការទទួលយកឯកសារពីក្នុងបញ្ជីឯកសាររបស់ភាគីនានាអាចធ្វើទៅបាន លុះត្រាតែមិនមានការជំទាស់ត្រូវបានទទួល

១២. នៅក្នុងអនុស្សារណៈនេះ អង្គជំនុំជម្រះសាកាលដំបូងបានដាក់កាលបរិច្ឆេទកំណត់ សំរាប់ការដាក់អញ្ញត្រកម្មបឋម ប្រសិនបើមាន ទៅនឹងភាពអាចទទួលយកបាននៃឯកសារដែលត្រូវបានស្វែងរកសុំឱ្យទទួលយកដោយភាគីបដិបក្ខនានា។ ចំណែកឯឯកសារនានាដែលបានស្នើសុំដើម្បីឱ្យទទួលយកដែលជាប់ទាក់ទងនឹងសាក្សីចំនួន៥រូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូបដែលអាចនឹងត្រូវកោះហៅនៅក្នុងអម្លុងពេលបីសប្តាហ៍ដំបូងនៃសវនាការជំនុំជម្រះក្តី ពេលវេលាកំណត់ត្រូវបានដាក់ឱ្យចំនួន១០ថ្ងៃគិតចាប់តាំងពីពេលជូនដំណឹងអំពីបញ្ជីឯកសាររបស់ភាគីនីមួយៗតទៅ។ ចំពោះឯកសារដែលនៅសេសសល់ ដែលត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសារសម្រាប់ដំណាក់កាលទីមួយរបស់ភាគីនានា កាលបរិច្ឆេទដែលត្រូវដាក់ គឺត្រូវបានកំណត់នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១២ សម្រាប់ការជំទាស់។

១៣. សហព្រះរាជអាជ្ញា សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងចេញជាសេចក្តីណែនាំមួយថា ឯកសារទាំងឡាយដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសាររបស់ភាគីនានា ដែលមិនមានការជំទាស់ពី

---

[14] *សូមអាន ឧទាហរណ៍ដូចជា* ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង *Jean-Paul Akayesu*, សំណុំរឿងលេខ ICTR-96-4-T, សេចក្តីសំរេចលើញត្តិរបស់រដ្ឋអាជ្ញាដែលស្នើសុំឱ្យពិនិត្យពិចារណាឡើងវិញ និងលប់ចោលជាមោឃៈនូវដីកាសំរេចចុះថ្ងៃទី២៨ មករា ១៩៩៧ (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR), ចុះថ្ងៃទី៦ មីនា ១៩៩៧ ត្រង់ទំព័រ៣ ។ *ករណីរឿងក្តីរបស់រដ្ឋអាជ្ញា ទល់នឹង Edouard Karemera, Mathieu Ngirumpatse, Joseph Nzirorera*, សំណុំរឿងលេខ ICTR-98-44-T, ដីកាបង្គាប់ជាបណ្តោះអាសន្នឱ្យខាងអយ្យការ កំណត់អត្តសញ្ញាណនូវអត្ថបទខ្លីៗដែលពាក់ព័ន្ធនៃឯកសារមួយចំនួន (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR), ចុះថ្ងៃទី៨ សីហា ២០០៧ ត្រង់កថាខណ្ឌទី២។

ភាគីណាផ្សេងទៀតនៅក្នុងរង្វង់ពេលវេលាកំណត់ទេនោះ គឺនឹងត្រូវបានទទួលយកជាភស្តុតាង ដោយមិនចាំបាច់មានការសួរដេញដោលបន្ថែមទៀតទេ និងមានលក្ខខណ្ឌចំពោះតែឯកសារទាំងឡាយណាដែលបាននឹងកំពុងតែកំណត់អត្តសញ្ញាណសមស្របនៅក្នុងតុលាការតែប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាសូមបំភ្លឺជូនថា គោលបំណងនៃសំណើសុំដូចខាងលើនេះ គឺសំរាប់តែឯកសារទាំងឡាយណាដែលត្រូវបានបញ្ជាក់អត្តសញ្ញាណរួចហើយ ដោយមានភាពជាក់លាក់គ្រប់គ្រាន់ ហើយដែលស្របទៅតាមសេចក្តីណែនាំ របស់អង្គជំនុំជម្រះសាលាដំបូង គួរតែត្រូវបានចាត់ទុកថាត្រូវបានស្នើសុំដោយភាគីនានា[15]។

១៤. ដូចដែលបានបកស្រាយដោយអង្គជំនុំជម្រះសាលាដំបូង តាមវិធានផ្ទៃក្នុង ភស្តុតាងទាំងអស់គឺសុទ្ធតែអាចទទួលយកបានឲ្យតែត្រូវទៅតាមបទដ្ឋានអប្បបរមានៃ ភាពទាក់ទង (relevance) និង ភាពអាចជឿទុកចិត្តបាន (reliability)[16]។ បទដ្ឋាននៃចំណុចចាប់ផ្តើមនេះមិនតម្រូវឲ្យមានអ្វី ច្រើនជាជាងការបង្ហាញថា ភស្តុតាងដែលបានផ្តល់ជូននោះគឺ *មើលមួយក្រឡេកភ្នែកទៅ (prima facie)* ទាក់ទងទៅនឹងបញ្ហានានានៅក្នុងជម្លោះ ហើយនិង *មើលមួយក្រឡេកភ្នែកទៅ (prima facie)* ជឿទុកចិត្តបាន។ អវត្តមាននៃការជំទាស់ទៅនឹង ភាពទាក់ទង (relevance) ឬមួយ ភាពអាចជឿទុកចិត្តបាន (reliability) នៃឯកសារជាក់លាក់ដែលបានលើកឡើងដោយភាគីជំទាស់នានា គេអាចសន្និដ្ឋានបានថាឯកសារទាំងនោះគឺត្រូវទៅតាមបទដ្ឋាននៃការទទួលយក។

១៥. បន្ថែមលើនេះ ដោយសារបញ្ជីឯកសាររបស់ភាគីនានាបានដាក់ជូនទៅអង្គជំនុំជម្រះសាលាដំបូងរួចហើយ អនុលោមតាមវិធាន៨០.៣ និងដែលគេបានផ្តល់ឱកាសឲ្យភាគីនានាធ្វើការលើកឡើងនូវការជំទាស់នៅពេលមុនមានសវនាការ ដោយអនុលោមតាមវិធាន៨០.៤ លក្ខខណ្ឌតម្រូវនៅក្នុងវិធាន៨៧.២ ដែលថាភស្តុតាងដែលបាន “ដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះ ត្រូវឆ្លងកាត់ការដេញដោល” អាចត្រូវបានបំពេញដោយឯកសារទាំងនោះ ដោយ គ្រាន់តែត្រូវបានកំណត់អត្តសញ្ញាណដោយលេខយោងឯកសារនៅក្នុងតុលាការ

---

[15] អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ថា បញ្ជីឯកសារនៅក្នុងសំណុំរឿងត្រូវមានដាក់បញ្ចូលនូវ លេខយោងឯកសារ, ចំណងជើងឯកសារ, ភាសាដែលអាចមាន ហើយថាបើសិនជាអាច ការរៀបរាប់សង្ខេបពីចរិតលក្ខណៈ និងខ្លឹមសាររបស់វា ដែលចុះបញ្ជីឯកសារថ្មីៗត្រូវមានដាក់បញ្ចូលនូវការរៀបរាប់សង្ខេបពីចរិតលក្ខណៈ និងខ្លឹមសាររបស់វា និងថា ឯកសារត្រូវភ្ជាប់ទៅនឹងផ្នែកដែលពាក់ព័ន្ធនៃដីកាដំណោះស្រាយ។ សូមមើល E9, ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ថ្ងៃទី១៧ មករា ២០១១ ត្រង់កថាខណ្ឌទី ១២-១៣ ។

[16] សូមមើលវិធាន៨៧.២ និង ៨៧.៣ ។ **E188** សាលក្រម, សំណុំរឿងលេខ ០០១, ថ្ងៃទី២៦ កក្កដា ២០១០ ត្រង់កថាខណ្ឌទី ៤១ ។ **E43/4** សេចក្តីសម្រេចស្តីពីភាពអាចទទួលយកសម្ភារៈដែលមាននៅក្នុងសំណុំរឿងធ្វើជាភស្តុតាង, សំណុំរឿងលេខ ០០១, ថ្ងៃទី២៦ ឧសភា ២០០៩ ត្រង់កថាខណ្ឌទី ៧ ។ **E176** សេចក្តីសម្រេចលើសំណើរបស់ភាគីនានាសុំដាក់សម្ភារៈមួយចំនួននៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធានផ្ទៃក្នុង៨៧(២), សំណុំរឿងលេខ ០០១, ថ្ងៃទី២៨ តុលា ២០០៩ ត្រង់កថាខណ្ឌទី ៣ ។

ជាឯករចន: ឬជាក្រុម ទៅតាមលក្ខណៈសមស្របរបស់វា[17]។ សហព្រះរាជអាជ្ញាសូមស្នើថា គេគួរតែធ្វើការកំណត់អត្តសញ្ញាណនេះនៅ ពេលចាប់បើកប្រជុំទៀងទាត់ដែលបានស្នើឡើង សម្រាប់លើកទឡ្ហីករណ៍ តទល់ដែលទាក់ទងទៅនឹងការទទួលយកឯកសារនានា (ដូចនៅក្នុងផ្នែក **គ** ខាងក្រោម) ។

១៦. វិធីសាស្ត្រនេះ គឺមានលក្ខណៈសមស្របយ៉ាងជាក់លាក់នៅក្នុងករណីរឿងបច្ចុប្បន្ននេះ បើគិតទៅដល់រយៈពេលវេលាដែលភាគីនានានឹងត្រូវធ្វើការពិចារណាលើឯកសារទាំងឡាយដែលបានដាក់ស្នើឡើងដោយភាគីជំទាស់នានា នៅពេលដែលការជំទាស់ត្រូវបានធ្វើឡើង ហើយនិងធ្វើការពិចារណាថា ភាគច្រើននៃឯកសារដែលបានស្នើឡើងនោះ សហចៅក្រមស៊ើបអង្កេតបានដាក់វាបញ្ចូលទៅក្នុងសំណុំរឿង នៅក្នុងរយៈពេលនៃការស៊ើបសួរដោយឯករាជ្យរបស់ពួកគាត់រួចស្រេចទៅហើយ។ វាក៏អាចបញ្ចៀសបានដោយមិនចាំបាច់ចំណាយពេលវេលាសវនាការ និងធនធានដ៏មានតម្លៃដើម្បីធ្វើការពិភាក្សាគ្នាអំពីភាពអាចទទួលយកបាននៃឯកសារ ដែលភាគីនានាមិនមានទំនាស់ ឬមិនមានមូលដ្ឋានដ៏គួរឲ្យព្រួយបារម្ភផ្សេងៗផងដែរ។

## គ. ការបែងចែកពេលវេលាទៀងទាត់សម្រាប់ការផ្តល់សំអាងផ្ទាល់មាត់ទាក់ទងទៅនឹងការទទួលយកឯកសារ

១៧. នៅក្នុងអនុស្សរណៈរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថាខ្លួននឹងផ្តល់ "ឱកាសឲ្យភាគីលើកទឡ្ហីករណ៍តទល់នៅក្នុងសវនាការបាន នៅក្នុងករណីចាំបាច់ដែលតម្រូវឲ្យធ្វើដូច្នោះ" ដែលទាក់ទងទៅនឹងការជំទាស់ទៅនឹងឯកសារ ឬវត្ថុតាងនានា ដែលបានស្នើសុំឲ្យទទួលយកដោយពាក់ព័ន្ធ នឹងសាក្សី ៥រូប និងដើមបណ្តឹងរដ្ឋប្បវេណី ៣រូប ដែលគេអាចនឹងកោះហៅនៅក្នុងអំឡុងពេលបី សប្តាហ៍ដំបូងនៃសវនាការ[18]។

១៨. ឱកាសឲ្យភាគីលើកទឡ្ហីករណ៍តទល់នេះ ត្រូវបានគេស្វាគមន៍ទាក់ទងទៅនឹងការជំទាស់នានាទៅនឹងការទទួលយកឯកសារដែលបានស្នើឡើងដោយភាគីនានា។ ជាផលវិបាក សហព្រះរាជអាជ្ញាសូមទទូចឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់កាលវិភាគពេលវេលា សម្រាប់លើកទឡ្ហីករណ៍តទល់បែបដូច្នេះ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីមានការដាក់ជូននូវការជំទាស់ និងការឆ្លើយតបទៅនឹងការជំទាស់ទាំងនោះ ដើម្បីឲ្យគេអាចធ្វើការដោះស្រាយអំពីភាពអាចទទួលយក

[17] ដូចបានកត់សម្គាល់ពីមុន វិធាន៨៧.៣ បញ្ជាក់ថាភស្តុតាងត្រូវបានពិចារណាថា បានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងកាលណាវា "ត្រូវបានសង្ខេប ត្រូវបានអាន ឬ ត្រូវបានកំណត់អត្តសញ្ញាណយ៉ាងសមស្របនៅក្នុងសវនាការ" ។

[18] **E131/1** អនុស្សរណៈ, ត្រង់ទំព័រទី ២ ។

បានឲ្យបានភ្លាមៗតាមដែលអាចធ្វើទៅបាននៅពេលសវនាការ ហើយនិង នៅមុនពេលសាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្ម ដែលគេអាចតម្រូវឲ្យធ្វើការយោងទៅដល់ឯកសារទាំងនោះ។ សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងចាត់ទុកដោយឡែកនូវពេលវេលាសម្រាប់ដំណាក់កាលដំបូងៗនៃសវនាការឲ្យបានទៀងទាត់ កាលណាមានការចាំបាច់ ត្រូវលើកទឡ្ហីករណ៍ផ្ទាល់មាត់។ វគ្គជាទៀងទាត់ទាំងនេះនឹងត្រូវចាប់ផ្តើមនៅបន្ទាប់ពីការដាក់ជូននូវការជំទាស់នានា (ប្រសិនបើមាន) នៅថ្ងៃទី៥ ខែមករា ឆ្នាំ២០១១ ទៅនឹងភាគីនានានៃបញ្ជីឯកសារដំណាក់កាលដំបូង ហើយនិងការដាក់ជូននូវចម្លើយតបទៅនឹងការជំទាស់ទាំងនោះ។ នៅក្នុងអំឡុងពេលនៃវគ្គទាំងនេះភាគីផ្តល់ឯកសារ និង ភាគីជំទាស់អាចនឹងធ្វើសេចក្តីសង្ខេបអំពីការលើកទឡ្ហីករណ៍ផ្ទាល់មាត់ទាក់ទងទៅនឹងភាពទាក់ទង (relevance) និង ភាពអាចជឿទុកចិត្តបាន (reliability) នៃឯកសារ ឬ ប្រភេទនានានៃឯកសារដែលគេបានជំទាស់។

១៩. ដូចបានកត់សម្គាល់ក្នុងចំណុច ខ ខាងលើកិច្ចប្រជុំដូច្នេះក៏អាចប្រើសម្រាប់ការកំណត់អត្តសញ្ញាណឯកសារដែលមិនមានការជំទាស់ ហើយឯកសារណាដែលសហព្រះរាជអាជ្ញាស្នើឡើងគួរតែបានទទួលយកដោយចាំបាច់សួរនាំបន្ថែមឡើយ។ នៅក្នុងព្រឹត្តិការណ៍ដែល អង្គជំនុំជម្រះសាលាដំបូងមិនយល់ស្របជាមួយនឹង សហព្រះរាជអាជ្ញាទាក់ទងទៅនឹងការទទួលយកឯកសារដែលគេមិនបានជំទាស់ (ដូចនៅក្នុងផ្នែក ខ ខាងលើ) កិច្ចប្រជុំបែបដូច្នោះក៏អាចត្រូវបានប្រើប្រាស់ដើម្បី លើកឡើងនូវសំណួរ ឬ កង្វល់នានាដែល អង្គជំនុំជម្រះសាលាដំបូង អាចនឹងលើកឡើងអំពីយោបល់របស់ខ្លួន ផ្ទាល់ទាក់ទងទៅនឹងភាពអាចទទួលយកបាននៃឯកសារបែបដូច្នោះ។ ដោយសារឯកសារមានចំនួនច្រើនសន្ធឹកសន្ធាប់ដែលភាគីផ្សេងៗបាន ដាក់ស្នើនោះ សហព្រះរាជអាជ្ញាសូមស្នើថាជាការសមស្របសុំឲ្យមានការបែងចែកពេលវេលា ប្រមាណជាកន្លះថ្ងៃរៀងរាល់សប្តាហ៍។ កាលវិភាគពេលវេលាទៀងទាត់ក្នុងការលើកឡើងពីភាពអាចទទួលបាននៃឯកសារ នឹងធានានូវការប្រព្រឹត្តទៅនៃសវនាការបានយ៉ាងរលូន និងឆាប់រហ័សដោយចៀសវាងផុតពីការរអាក់រអួលព្រមទាំង សំអាងនានានៅលើចំណុចច្បាប់នៅក្នុងអំឡុងពេល នៃការផ្តល់សក្ខីកម្មរបស់សាក្សី។

## ឃ. ការចាត់លេខឯកសារ E3

២០. ជាបញ្ហានីតិវិធីចុងក្រោយ សហព្រះរាជអាជ្ញា សូមស្នើថា នៅពេលធ្វើការទទួលយកឯកសារណាមួយធ្វើជាភស្តុតាង គេត្រូវតែដាក់លេខឯកសារទាំងនោះថា E3 ក្នុងគោលបំណងដើម្បីឲ្យមានលេខយោងដូចគ្នា និងដើម្បីជួយសម្រួលដល់គ្រប់ភាគីទាំងអស់ឲ្យបានប្រើប្រាស់ភស្តុតាងជាឯកសារទាំងនោះនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីសវនាការ ។

## IV. សំណងជូនដល់ដែលបានស្នើសុំ

២១. អាស្រ័យមូលហេតុដូចដែលបានលើកឡើងខាងលើនេះ សហព្រះរាជអាជ្ញា សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង៖

(១) បញ្ជាក់ថា ភាគីនានានឹងត្រូវបានអនុញ្ញាតឲ្យដាក់ឯកសារផ្សេងៗជូនអង្គជំនុំជម្រះសាលាដំបូង ដោយផ្ទាល់ជាបន្ថែមពីលើឯកសារដែលផ្តល់ជូនតាមរយៈសាក្សីនានា។

(២) បង្គាប់ថា ការឯកសារទាំងឡាយដែលបានដាក់បញ្ចូលនៅក្នុងបញ្ជីឯកសាររបស់ភាគីនានាដែលមិនមានការជំទាស់ពីភាគីបដិបក្ខ គួរបានទទួលយកជាភស្តុតាងដោយមិនចាំបាច់មានការសួរដេញដោលបន្ថែមទៀត។

(៣) កំណត់បែងចែកជាសវនាការជាទៀងទាត់ នៅក្នុងអម្លុងពេលសវនាការសម្រាប់ការលើកទទ្បីករណ៍តទល់គ្នាដែលត្រូវបើកធ្វើទៅលើអញ្ញត្រកម្មបឋមណាមួយចំនួនដោយភាគីនានា ឬទៅលើការព្រួយបារម្ភផ្សេងៗ ដែលបានលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូងខ្លួនឯងផ្ទាល់ ដូចជាអំពី ឯកសារដោយឡែកណាមួយ ។ និង

(៤) ដាក់ជាបន្ទាន់នូវលេខ E3 លើឯកសារទាំងឡាយណាដែលត្រូវបានទទួលយក ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |